ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.......

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០២០

## ជម្រាបជូន
## ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**កម្មវត្ថុ:** ករណីសំណើសុំកំណត់នីតិវិធីចំណាយថវិកា និងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

**យោង:** -លិខិតលេខ៧៤៣២ អយក.អកត ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា
-របាយការណ៍កិច្ចប្រជុំអន្តរក្រសួងកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការពិភាក្សាអំពីនីតិវិធីចំណាយថវិកានិងការគ្រប់គ្រងមត្តេយសហគមន៍ដែលមានលក្ខណៈស្តង់ដា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជ្រាបថា បន្ទាប់ពីបានពិនិត្យលើជម្រើស និងសំណើដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំអន្តរក្រសួងរវាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ កន្លងមក ដើម្បីគោរពសុំការពិនិត្យ និងសម្រេចលើទិដ្ឋភាពបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមផ្តល់គោលការណ៍ដូចខាងក្រោម÷

**១). <u>ចំណាយប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា</u>**

ក- សម្រាប់ឆ្នាំ២០២០

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់អនុគណនី ៦៤០៤១ (បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា) សម្រាប់កត់ត្រាចំណាយប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ដោយសារឥណទានថវិកាត្រូវបានគ្រោងក្នុងអនុគណនីនេះរួចទៅហើយ។ ទន្ទឹមនេះក្រសួងអប់រំ យុវជន និងកីឡា ត្រូវស្នើសុំក្រសួងមុខងារសាធារណៈ ជាករណីពិសេស សម្រាប់តែឆ្នាំ ២០២០ ដើម្បីផ្តល់ជូនគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា នូវបុព្វសិទ្ធិដូចជាមន្ត្រីជាប់កិច្ចសន្យាក្នុងក្របខណ្ឌមុខងារសាធារណៈ។

ខ- សម្រាប់ឆ្នាំ២០២១ និងឆ្នាំបន្តបន្ទាប់

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវប្រើប្រាស់អនុគណនី ៦១០៩៣(បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ) សម្រាប់បើកផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែជូនគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

**២). <u>ចំណាយសម្រាប់កិច្ចដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា</u>**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានផ្តល់គោលការណ៍ ដូចខាងក្រោម÷


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ក- អនុញ្ញាតឱ្យប្រើប្រាស់អនុគណនី ៦០០២៨ (សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ) សម្រាប់មុខសញ្ញាចំណាយលើកិច្ចដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍។

ខ- អនុញ្ញាតឱ្យធ្វើនិយ័តភាពឥណទានថវិកាពីអនុគណនី ៦០០២១ (សម្ភារៈការិយាល័យ) មកអនុគណនី ៦០០២៨ (សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ) សម្រាប់ឆ្នាំ ២០២០ ឱ្យបានឆាប់រហ័ស សម្រាប់ចំណាយលើកិច្ចដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។

គ- ថវិកាសម្រាប់សម្រាប់កិច្ចដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា មានចំនួន ៥០ ម៉ឺនរៀល ក្នុងមួយឆ្នាំ។ ថវិកានេះ ត្រូវផ្តល់ជូន ២ ដង ក្នុងមួយឆ្នាំ ដោយបង្វែរថវិកាចូលក្នុងគណនីធនាគាររបស់គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា។ ទន្ទឹមនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់ការបណ្តុះបណ្តាលជូនគ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា អំពីការប្រើ-ប្រាស់ថវិកាសម្រាប់កិច្ចដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងការរៀបចំរបាយការណ៍ចំណាយ ដើម្បីធានានូវគណនេយ្យភាព និងតម្លាភាពនៃការប្រើប្រាស់ថវិកា។

**៣). <u>ថវិកាសម្រាប់ឧបត្ថម្ភជូនគ្រូមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា ក្នុងអំឡុងពេលចូលរួមការ-បណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា</u>**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់អនុគណនី ៦២០២៥ (អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស) សម្រាប់ឧបត្ថម្ភជូនគ្រូមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាដែលចូលរួមការបណ្តុះបណ្តាលអភិវឌ្ឍន៍ សមត្ថភាពដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយកំណត់អត្រាឧបត្ថម្ភតាមស្មារតីលិខិតលេខ ២៨៧ សហវ.ហក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការបន្ថែមវិសាលភាពមួយចំនួនដើម្បីអនុវត្តការចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសនៅក្រសួងអប់រំ យុវជន និងកីឡា ដែលធ្លាប់បានអនុវត្តសម្រាប់ការឧបត្ថម្ភសិស្ស និស្សិតដែលមិនមែនជាមន្ត្រីរាជការ ដើម្បីបំប៉ននិងសិក្សាស្រាវជ្រាវក្នុងប្រទេស។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន÷</u>
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
- ឯកសារ-កាលប្បវត្តិ